# ការគ្រប់គ្រងថ្នាក់រៀន

(CLASSROOM MANAGEMENT)

ដោយ៖ **បណ្ឌិត សូ សុធីរ**
មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
រាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

ការគ្រប់គ្រងថ្នាក់ សំដៅទៅលើយុទ្ធសាស្ត្រ និងបច្ចេកទេស ដែលគ្រូប្រើដើម្បីបង្កើតបរិយាកាសសិក្សា ដែលមានការរៀបចំប្រសិទ្ធភាពនិងវិជ្ជមាន។វាពាក់ព័ន្ធនឹងការកំណត់ការរំពឹងទុកច្បាស់លាស់ ការរក្សាវិន័យ ជំរុញការចូលរួមរបស់សិស្ស និងជានាបានទូវការផ្លាស់ប្តូរ ដោយរលូនរវាងសកម្មភាពនានា។ ការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាពបង្កើនការរៀនសូត្ររបស់សិស្ស កាត់បន្ថយការរំខាន និងលើកកម្ពស់បរិយាកាសគោរព និងសហការ។ តាមរយៈការអនុវត្តទម្លាប់ដែលមានរចនាសម្ព័ន្ធ ការកសាងទំនាក់ទំនាក់ទំនងគ្រូសិស្សរឹងមាំ និងប្រើប្រាស់យុទ្ធសាស្ត្រសកម្ម អ្នកអប់រំ អាចបង្កើតបរិយាកាស ដែលសិស្សមានអារម្មណ៍ថាមានសុវត្ថិភាព លើកទឹកចិត្ត និងត្រៀមខ្លួនជាស្រេចដើម្បីរៀន។

### ១-ទំនាក់ទំនងគ្រូ-សិស្ស

ទំនាក់ទំនងគ្រូសិស្សល្អ គឺពឹងផ្អែកទៅលើការគោរពគ្នាទៅវិញទៅមក។ សិស្សគោរពគ្រូ ដោយសារតែបំណិនបង្រៀនរបស់គាត់ (Teaching skills) គុណសម្បត្តិបុគ្គល (Personal qualities) ចំណេះដឹង (Knowledge) និងវិជ្ជាជីវនិយម (Professionalism)។ គ្រូគោរពសិស្សក្នុងនាមជាបុគ្គលម្នាក់ និងសិស្សមានអារម្មណ៍រៀនសូត្រ។ វាជារឿងសំខាន់ដើម្បីដឹងថា ការគោរពសិស្ស ដែលជាបុគ្គលម្នាក់ មិនដូចគ្នានឹងការគោរពសិស្សក្នុងថ្នាក់រៀនទាំងមូលនោះទេ ហើយការគោរពរបស់គ្រូ ត្រូវតែបង្ហាញតាមអារម្មណ៍ បើមិនដូច្នោះទេ សិស្សនឹងមិនបានដឹងអំពីរឿងនេះទេ។

#### ក-ទំនាក់ទំនងគ្នាយ៉ាងល្អ និងអំណាចផ្លូវការ

ទំនាក់ទំនងគ្នាយ៉ាងល្អ ត្រូវការពេលវេលាមួយយ៉ាងសមរម្យ ដែលជា

ទូទៅ ត្រូវឆ្លងតាមដំណាក់កាល២។ នៅក្នុងដំ ណាក់កាលដំបូង គ្រូសម្រេចបានស្ថានភាពអំណាចដោយគុណធម៌តាមតួនាទីជាគ្រូ។ ប្រសិនបើសិស្ស ទំនងជាមិនស្តាប់បង្គាប់អ្នកទេ គ្រូត្រូវធ្វើសំណូមពរភ្លាមៗ។

លោក ដេវីត ហាហ្គ្រីវស៍ (David Hargreaves) ជាចិត្តវិទូសង្គម ផ្នែកវិស័យអប់រំ ផ្តល់យោបល់ថា គ្រូដែលចាប់ផ្តើមបង្រៀនថ្នាក់ថ្មី ត្រូវតែដឹងថា តើសិស្សទទួលយកអំណាចផ្លូវការរបស់គាត់ដែរឬទេ។ គ្រូ ត្រូវតែដឹងថាអំណាចរបស់ខ្លួន ជាអំណាចស្របច្បាប់ ដើម្បីធ្វើឱ្យការសិក្សាមានការរីកចម្រើនជាអតិបរិមា ហើយគ្រូត្រូវបង្ហាញទំនុកចិត្ត (Confidence) នៅក្នុងបំណិនរបស់ខ្លួន ដើម្បីពង្រឹងអំណាចនេះ។

គ្រូ មិនអាចរំពឹងថា សិស្សចូលចិត្តមេរៀនដំបូងរបស់ខ្លួនទេ។ គាត់មិនមានបទពិសោធទៅវិញទៅមក ដែលអាចបង្កើតទំនាក់ទំនងបុគ្គល។ ដូច្នេះ ចូលចិត្ត ឬមិនចូលចិត្តក៏ដោយ គ្រូនឹងចាប់ផ្តើមនៅក្នុងទំនាក់ទំនងផ្លូវការ ជាមួយថ្នាក់រៀនរបស់ខ្លួន។ គ្រូបង្រៀនត្រូវបានគេផ្តល់ភារកិច្ចសមរម្យ តែជាតួនាទីត្រឹមត្រូវ។ គ្រូត្រូវគោរពសិទ្ធិធ្វើការងារ និងអាកប្បកិរិយានិយាយស្តីត្រឹមត្រូវ។ គ្រូថ្មីៗមួយចំនួនមានអារម្មណ៍ពិបាកសម្របតាមក្នុងស្ថានភាពនៃអំណាចបែបនេះ ប្រហែលជាគេមិនធ្លាប់បានឆ្លងកាត់រឿងនេះ ហើយជាលើកដំបូង សិស្សគោរពធ្វើតាមបទបញ្ជាមួយដែលគួរឱ្យភ្ញាក់ផ្អើល។ ហេតុអ្វីបានជាអ្នកមានអារម្មណ៍អៀនខ្មាស ឬអត់ឱនទោសអំពីការប្រើប្រាស់អំណាចផ្លូវការរបស់គ្រូ ប្រសិនបើវាកំពុងប្រើប្រាស់វា សម្រាប់ប្រយោជន៍សិស្ស? អ្នកនៅទីនេះ ដើម្បីបង្រៀន ហើយអ្នកមិនអាចបង្រៀនដោយគ្មានបទបញ្ជា ឬសណ្តាប់ធ្នាប់ទេ ចូរប្រើប្រាស់អំណាចរបស់អ្នក។

តើអ្នកអភិវឌ្ឍ និងប្រើប្រាស់អំណាចផ្លូវការនេះយ៉ាងដូចម្តេច? រឿងនេះអាស្រ័យទៅលើស្ថានភាពបង្រៀន។ ប្រសិនបើសិស្សអ្នកមិនមានភាពសហការទេ អញ្ចឹងអ្នកអាចរកឃើញដោយខ្លួនឯងយ៉ាងជាក់លាក់នៅក្នុងការផ្តោតអារម្មណ៍ដូចតទៅ៖

សិស្សរបស់អ្នកនឹងទទួលយកតែអំណាចរបស់អ្នក ប្រសិនបើអ្នកអនុវត្តវាដោយមានទំនុកចិត្ត។ ទោះជាយ៉ាងណាក៏ដោយ អ្នកគ្រាន់តែចាប់ផ្តើមមានទំនុកចិត្តនៅពេលដែលគេទទួលយកអំណាចរបស់អ្នក។

ជាបឋម គ្រូត្រូវតែធ្វើសកម្មភាព។ ចូរដើរពាសពេញបន្ទប់រៀនដោយជំហាន

វែង។ ធ្វើហាក់ដូចជាអ្នកមានទំនុកចិត្តទាំងស្រុងពីសមត្ថភាពរបស់ខ្លួន ដើម្បីគ្រប់ គ្រងក្រុម។ បង្ហាញនូវស្ទ័យទំនុកចិត្តបន្ធូរអារម្មណ៍ និងគ្រប់គ្រងខ្លួន ជាពិសេសនៅពេលដែលអ្នកមិនមានអារម្មណ៍បែបនេះ។ នេះជារឿងសំខាន់ពិសេស នៅក្នុងមេរៀនដំបូងៗរបស់អ្នក ឬនៅពេលដែលអ្នកដោះស្រាយបញ្ហាលំបាក។

អំណាចជាផ្លូវការ ត្រូវបានគេទ្រទ្រង់ដោយវិធីមិនមែនប្រើប្រាស់ពាក្យសម្តី (Non-verbal methods)។ ក្រោកឈរឱ្យត្រង់ខ្លួន ស្មាទៅក្រោយ សម្លឹងមើលមុខសិស្សឱ្យចំ ផ្តល់បទបញ្ជាដោយមានទំនុកចិត្ត ហើយរំពឹងថា នឹងទទួលបានការគោរព។ ប្រសិនបើអ្នកសុំសិស្សឱ្យធ្វើអ្វីមួយ កុំឈរផតកម្រើក ដោយមានទឹកមុខអន្ទះសារ ឆ្ងល់ថាតើនឹងមានអ្វីកើតឡើងនៅពេលបន្ទាប់មកទៀត។ ចូរដាក់បទបញ្ជា ដោយមានទំនុកចិត្ត។ ប្រសិនបើសិស្សអ្នកមិនបានធ្វើអ្វី ដូចដែលអ្នកបានសុំតាមពេលវេលាសមរម្យនោះទេ ចូរមានទំនុកចិត្ត និងបញ្ជាក់ឱ្យជាកលាក់។អ្នកអាចបង្ហាញការភ្ញាក់ផ្អើលដោយចម្ងល់នូវពាក្យទ្រគោះបោះបោក (Impertinence) ប៉ុន្តែកុំបង្ហាញថាអ្នកមានភាពស្មុគស្មាញ។

អំណាចត្រូវបានធ្វើជាសំខាន់តាមភាសាកាយវិការ (Body language)។ ជាឧទាហរណ៍ ចូរប្រៀបធៀបរបៀបដោះស្រាយ ២យ៉ាងពីសិស្សដែលមិនប្រឹងប្រែងសិក្សា៖

១-មិនសម្លឹងមើលមុខសិស្ស ហើយឈរនៅចម្ងាយ៩ម៉ែត្រ ដោយនិយាយថា ខ្ញុំចង់ឱ្យអ្នកឈប់និយាយ ហើយចាប់ផ្តើមសិក្សាឥឡូវនេះ។

២-ដើរដោយមានទំនុកចិត្ត ប៉ុន្តែមិនត្រូវប្រញាប់ប្រញាល់ទៅកាន់សិស្ស ដោយដាក់ដៃទាំង២ទៅលើតុ ទ្រោបខ្លួនទៅមុខ ហើយសម្លឹងមុខសិស្សត្រង់កែវភ្នែកឱ្យបាន៣វិនាទី បន្ទាប់មកនិយាយថា ហេតុអ្វីមិនចាប់ផ្តើមរៀនទៅ? ហើយនៅតែសម្លឹងមើលសិស្ស។

វិធីទាំង២នេះ បង្កើតនូវផលផ្សេងគ្នាគួរឱ្យភ្ញាក់ផ្អើល ទៅលើសិស្ស។ សួរសិស្សឱ្យសាកល្បងទៅលើអ្នក ប្រសិនបើអ្នកមិនជឿទេ។

ជាការពិតហើយ អ្នកមិនចាំបាច់ប្រឹងប្រែងដាក់បទបញ្ជាខ្លាំងពេកទេ ប៉ុន្តែចូរចាំថា នៅពេលណា ដែលកំពុងបង្រៀន ផលទៅលើសិស្ស មានការកើនឡើងនោះ ចូរកុំស្រែក ឬមានកំហឹងឱ្យសោះ ប៉ុន្តែ៖

**១-ភាពចូលទៅជិត** (Proximity) អ្នកកាន់តែចូលទៅជិត ផលទទួលកាន់តែច្រើន ជាពិសេស ប្រសិនបើអ្នកចូលទៅដល់កន្លែងទំនេររបស់សិស្ស និងស្ថិតក្នុង

ស្ថានភាពបែបបញ្ជា (A commanding posture)។

**៣-ទំនាក់ទំនងតាមកែវភ្នែក** (Eye contact) នោះគឺថា ជួយទ្រទ្រង់កែវភ្នែកអ្នក នៅពេលនិយាយ និងជួយលើកកម្ពស់ផល មុនពេល និងក្រោយពេលបាននិយាយ។

**៣-ចោទសួរជាសំណួរ** (Posing a question) ជាញឹកញាប់ វាមានឥទ្ធិពលខ្លាំង ដើម្បីចោទសួរ សិស្សនូវសំណួរ ជាងបង្រៀនដោយអធិប្បាយមេរៀនមួយ។ ទោះជាយ៉ាងនេះក្តី ជួនកាលគេធ្វើរឿងនេះ បានប្រសើរបំផុត ពេលដែលមានសិស្សតែម្នាក់។ ឧទាហរណ៍ ហេតុអ្វីបានជាអ្នកមិនចាប់ផ្តើមទៅ?

ការជំរុញលើកទឹកចិត្តទាំង៣ខាងលើ អាចត្រូវចងចាំដោយលំនឹកមេកានិក។ ដោយការប្រើប្រាស់វាបានល្អនោះ អ្នកអាចធ្វើឱ្យខ្លឹមសារមានថាមពល។ ជាទូទៅ ភាពចូលជិត និងទំនាក់ទំនង តាមមកែវភ្នែក គឺមានភាពគ្រប់គ្រាន់ ដោយមិនចាំបាច់ចោទសួរជាសំណួរឡើយ។ វាគួរតែត្រូវបានសាកល្បងជាលើកដំបូង ដោយមានអំណះអំណាងជាវិជ្ជមាន ដូចជាលឿនឡើង ចាប់ផ្តើមរៀនទៅ មុនពេលផ្សំវាជាមួយសំណួរ។

ប្រសិនបើអ្នកប្រើប្រាស់គោលវិធីបង្រៀន មានប្រសិទ្ធភាពនោះ អ្នកនឹងចាំបាច់ដំឡើងសំឡេងតិចតួចដើម្បីធ្វើឱ្យផលនៃការបង្រៀនមានកម្រិតជាអតិបរិមា។ តាមពិតទៅ អ្នកនឹងបង្កើតឱ្យមានភាពចាប់អារម្មណ៍ដោយបន្ទាបសំឡេង។

ប្រសិនបើអ្នកគិតថា មានកង្វល់ ចូរកុំអង្គុយនៅខាងក្រោយតុ ចូរដើរជុំវិញថ្នាក់រៀន ហើយប្រើប្រាស់ទំនាក់ទំនងតាមកែវភ្នែក។ ប្រសិនបើមានការនិយាយឥតបានការ ធ្វើចលនាតាមផ្នែកខ្លះនៃថ្នាក់រៀន ហើយធ្វើទំនាក់ទំនងតាមកែវភ្នែក។

អ្នកមិនចាំបាច់មានកម្ពស់ខ្ពស់ទេ គ្រូដែលមានវិន័យកម្រិតខ្ពស់បំផុត ដែលគេធ្លាប់ជួបប្រទះ គឺអ្នកគ្រូដែលមានកម្ពស់មិនខ្ពស់ជាង១.៥ម.ទេ។ គាត់គ្រាន់តែឈរត្រង់ខ្លួន ហើយសម្លឹងមើលដោយមានទំនុកចិត្ត។ កុំមានការជឿជាក់ពេកទៅលើការបង្ខំដោយប្រើអំណាចផ្លូវការ តាមរបៀបនេះ។ មេរៀនគួរឱ្យចាប់អារម្មណ៍ ទំនាក់ទំនងល្អ និងការគ្រប់គ្រងថ្នាក់រៀនបានល្អ មានប្រសិទ្ធភាពជាងក្នុងការរក្សាសណ្តាប់ ដូចដែលអ្នកនឹងឃើញនៅក្នុង២ ឬ៣ទំព័រខាងមុខទៀត។ ប្រសិនបើអ្នកមានបញ្ហាដំបូន្មានទៅលើវិន័យនាពេលក្រោយ ក្នុងជំពូកនេះ អាចជួយអ្នកបាន។ កុំភ័យខ្លាចពីអមិត្តក្នុងរយៈពេលខ្លី។ អ្នក

ត្រូវតែបង្ហាញថា អ្នកមិនខ្លាចពីភាពមិនមានប្រជាប្រិយទេ ប្រសិនបើអ្នកមានប្រជាប្រិយ។

### ខ-ទំនាក់ទំនងល្អ និងអំណាចបុគ្គល

ដំណាក់កាល២ក្នុងការអភិវឌ្ឍទំនាក់ទំនងគ្រូសិស្សគឺជាការផ្លាស់ប្តូរបន្តិចម្តងៗ ពីអំណាចជាផ្លូវការនេះ ទៅកាន់អំណាចបុគ្គលរបស់គ្រូ។ គ្រូបង្រៀនដែលគ្រប់គ្រងអំណាចផ្លូវការបានត្រឹមត្រូវ និងមានប្រសិទ្ធភាពនោះ បង្ហាញបំណិនមួយចំនួនក្នុងការបង្រៀន ហើយបង្ហាញថាគេវាយតម្លៃសិស្ស និងការប៉ុន ប៉ងដើម្បីសិក្សានោះ នឹងទទួលបានការគោរពពីសិស្សរបស់ខ្លួន។ ប្រសិនបើទាំងអស់នេះដំណើរការល្អ ពេលវេលាផ្តល់ឱ្យទំនាក់ទំនង អាចផ្លាស់ប្តូរ ដើម្បីឱ្យវាមានមូលដ្ឋានទៅលើបុគ្គលិកលក្ខណៈ។ ប្រភពនៃអំណាចរបស់គ្រូ ក្លាយជាសេចក្តីប្រាថ្នាដល់សិស្ស ដើម្បីធ្វើឱ្យគ្រូសប្បាយចិត្ត និងដើម្បីបង្កើតរូបភាពផ្ទាល់ខ្លួន តាមការយល់ស្របរបស់គ្រូ។

តើអំណាចបុគ្គលនេះ មានការពាក់ព័ន្ធយ៉ាងដូចម្តេចខ្លះ? វាត្រូវការរយៈពេលច្រើនខែ ជាជាងច្រើនសប្តាហ៍។ ជាក់ស្តែង គ្រូនឹងទទួលបានការគោរពពីសិស្ស ដោយធ្វើជាគ្រូដ៏មានប្រសិទ្ធភាព ប៉ុន្តែចំណុចដូចតទៅនេះ នឹងជួយគ្រូបាន៖

១-ការបង្ហាញចំណូលចិត្តពិតៗ នៅក្នុងការសិក្សារបស់សិស្ស និងបង្កើតចំណុចសរសើរ ជាពិសេស ក្នុងការទទួលស្គាល់នូវការរួមចំណែកបុគ្គលសិស្សម្នាក់ៗ ឬការប៉ុនប៉ងដើម្បីសិស្ស ដោយមិនគិតពីការទទួលបានចំណេះដឹងពីពេលមុន ឬសមត្ថភាពពីកំណើត (Innate ability)។

២-ភាពមានច្បាប់ច្បាស់លាស់ និងអនុវត្តវាឱ្យបានត្រឹមត្រូវ និងតឹងរ៉ឹង ដោយមិនមានការច្រណែន ពីថ្នាក់មួយទៅមួយទៀត។

៣-ការប្រើប្រាស់ឈ្មោះសិស្ស។

៤-ការបង្ហាញការគោរពគួរសមធម្មតា ចំពោះសិស្សដោយនិយាយថា សូម និងអរគុណ។

៥-ចូរកុំប្រើប្រាស់ការចំអកបញ្ឈឺចិត្តឱ្យសោះ (sarcasm)។

៦-មានគោលវិធីតាមដំនាញ ចំពោះការបង្រៀន និងការចាត់តាំងរបស់អ្នក ដូចជាមេរៀន រៀបចំបានល្អត្រឹមត្រូវ ការរក្សាបានតាមពេលវេលា មានសណ្តាប់ធ្នាប់...។

៧-ចូរមានចិត្តអត់ធ្មត់។

៨-ជ្រើសរើសវិធីបង្រៀន ដែលនាំឱ្យសិស្សបានរួមចំណែកផ្ទាល់ខ្លួន និងប្រតិកម្មដោយវិជ្ជមាន ទៅនឹងរឿងទាំងនេះ នៅពេលដែកអ្នកអាច។

៩-បង្ហាញចំណូលចិត្តនៅក្នុងតម្រូវការ អារម្មណ៍ និងឥរិយាបថសិស្សៈ គិតដល់បណ្ណាល័យថ្មី ព្រួយបារម្ភពីលំហាត់ពិបាក យល់មេរៀនច្បាស់លាស់។

បន្ថិចក្រោយមកៈ

១-បង្ហាញចំណូលចិត្តទៅលើសិស្សម្នាក់ៗ ដូចជា ការញញឹម ការប្រើប្រាស់ទំនាក់ទំនងតាមកែវភ្នែក និងនិយាយទៅកាន់គេម្នាក់ម្តងៗ។ ទទួលស្គាល់បុគ្គលភាពរបស់សិស្សម្នាក់ៗ ដូចជា គំរូបុគ្គលិកលក្ខណៈចំណូលចិត្ត រចនាបថសម្លៀកបំពាក់។

២-អភិវឌ្ឍបែបបទគួរទុកចិត្ត និងផ្លូវអារម្មណ៍ ដែលមិនមានលក្ខណៈផ្លូវការពេក ដោយប្រើប្រាស់អារម្មណ៍សមរម្យ។ ចូរកំប្លែង ដើម្បីបង្ហាញនូវទំនុកចិត្ត។

ភាគច្រើននៃរឿងខាងលើ ងាយបង្ហាញថា អ្នកវាយតម្លៃសិស្សអ្នកទៅតាមបុគ្គល ឬវាយតម្លៃ គេទៅតាមស្នាដៃ ឬកិច្ចសហការ។ ប្រសិនបើអ្នកទទួលបានជោគជ័យទៅលើការបង្កើតឱ្យមានចុះសម្រុងគ្នានោះ ការងាររបស់អ្នកនឹងធ្វើឱ្យមានភាពងាយស្រួលជាង ព្រមទាំងមានភាពគួរជាទីរីករាយផង។ រង្វាន់ចម្បងៗនៃការបង្រៀន គឺស្ថិតនៅក្នុងទំនាក់ទំនងរបស់គ្រូ និងសិស្សរបស់ខ្លួន។

តើអ្នកមានភាពលំបាកនឹងចាំឈ្មោះសិស្សឬទេ? ពិតជាមាន ប៉ុន្តែ ខ្ញុំមានសហសេវិកម្នាក់ ដែលបានចងចាំគ្រប់ឈ្មោះសិស្សទាំងអស់ តាំងតែពីសប្តាហ៍ដំបូងនៃឆ្នាំសិក្សាថ្មី ដូច្នេះ ខ្ញុំបានសួរគាត់ពីរបៀបចងចាំនេះ។ ចូរចងចាំថា ភាពញឹកញាប់ និងភាពថ្មីៗ (frequency and recency) ជាសញ្ញាបង្ហាញដល់ការសិក្សាដើម្បីទទួលបានលំនឹកល្អ។ គាត់បានធ្វើប្លង់ថ្នាក់រៀនមួយ ដោយមានសរសេរឈ្មោះសិស្សពេញលេញ នៅកន្លែងដែលគេបានអង្គុយ។ គាត់បានអានវាទាំងអស់ជាច្រើនដងក្នុងមួយថ្ងៃ ទោះបីជាគាត់មិនចាំមុខសិស្សទាំងនោះក៏ដោយ។ គាត់បានចំណាយពេលជាច្រើននាទី មើលប្លង់ថ្នាក់រៀន មុនពេលគាត់ចូល បង្រៀន និងជាពិសេសក្រោយពេលបង្រៀនផងដែរ នៅពេលដែលគាត់នៅតែអាចចងចាំមុខរបស់គេនៅឡើយ។ គាត់ដាក់ប្លង់សិស្សនៅក្នុងថ្នាក់រៀននៅលើតុ ហើយប្រើប្រាស់ឈ្មោះសិស្សនៅពេលដែលគាត់និយាយទៅកាន់ពួកគេ។

ប្រសិនបើមិនមានភាពចុះសម្រុងគ្នា កើតមានឡើងនៅក្នុងថ្នាក់រៀនទេនោះ របាំងចិត្តសាស្ត្រមួយ ត្រូវបានបង្កើតដែលរាំងស្កាត់ដល់សិស្សក្នុងការចូលរួមពិភាក្សា សួរសំណួរ ឬសុំជំនួយផ្សេងៗ។

ទៀត។ វាធ្វើឱ្យខូចប្រយោជន៍ចលករសិក្សារបស់សិស្ស និងការគ្រប់គ្រងថ្នាក់រៀន (Student motivation and classroom management)។ ឈ្មោះ ភាពញញឹម និងសិទ្ធិស្មើគ្នា គឺជារបៀបដ៏មានប្រសិទ្ធភាពបំផុត ក្នុងការជានារបាំងនេះ មិនកើតមាន និងរីកចម្រើន។

ចូរកុំព្យាយាមខ្លាំងពេកនឹងភាពចុះសម្រុងគ្នានេះ។ សិស្សនឹងមិនចូលចិត្តអ្នក ប្រសិនបើអ្នកមិនសង្ឃឹមថាគេចូលចិត្ត។ កុំសង្ឃឹមខ្លាំងពេក។ សិស្សរបស់អ្នកមិនចង់ឱ្យអ្នក ក្លាយជាមិត្ត ឬអ្នកជំនិតដ៏ល្អបំផុតនោះទេ។ ពួកគេបានយល់ដឹងរឿងនេះរួចមកហើយ។ អ្វីទាំងអស់ដែលគេចង់បានគឺថា អ្នកគួរតែអនុវត្តឱ្យ មានប្រសិទ្ធភាព នៅក្នុងការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀនរបស់ខ្លួន ហើយអ្នកគួរតែមានទំនាក់ទំនងល្អ និងមានចំណូលចិត្តពិតប្រាកដ នៅក្នុងការសិក្សារបស់ពួកគេ។

អ្នកនឹងមិនអាចបង្កើតភាពចុះសម្រុងជាមួយគ្នាបានទេ ប្រសិនបើអ្នកមិនអាចគ្រប់គ្រងថ្នាក់រៀន ដោយមានប្រសិទ្ធភាពនោះ។

គេបានធ្វើការសាកសួរនិស្សិតសាកលវិទ្យាល័យមួយ ដើម្បីឱ្យគេបញ្ចេញយោបល់ថា តើទម្លាប់បង្រៀនបែបណាដែលពួកគេមិនចូលចិត្ត។ ចម្លើយរបស់ពួកគេគឺ៖

-ការមិនយកចិត្តទុកដាក់ដក់និស្សិតទាំងឡាយ

-ការដាក់សំណួរតឹងតែង និងធ្វើឱ្យគេបាក់ទឹកចិត្ត។

-ការចំអកដល់ការចូលរួមចំណែករបស់សិស្ស។

-ការចំអកបញ្ឈឺចិត្ត និយាយមើលងាយគ្នា ភាពអមិត្ត ឬកំហឹង។

-ការវាយឫក (Arrogance)។

-ការបង្អាក់ ឬការរំខានដល់ការរួមចំណែករបស់សិស្ស។

-ការបរាជ័យ ដើម្បីជំរុញដល់ការពិភាក្សា ឬសំណួរ។

ការស្រាវជ្រាវនេះមិនមាននិយាយអំពីការចុះសម្រុងគ្នាជាពិសេសនោះទេ ប៉ុន្តែចូរកត់សម្គាល់ថា ទម្លាប់បង្រៀនដែលមិនគួរឱ្យចូលចិត្តទាំងអស់ គឺបង្ហាញផលនៃការខ្វះខាតរបស់គ្រូ ដើម្បីការគោរពដល់ចំណូលចិត្តសិស្ស។

## ២-ការបង្កើតបរិយាកាសសិក្សាក្នុងថ្នាក់រៀន

សិស្ស គឺជាអ្នកទទួលផល មិនមែនជាជនរងគ្រោះនៃការគ្រប់គ្រងថ្នាក់រៀនដ៏មានប្រសិទ្ធភាព។

ថ្ងៃមួយក្នុងអំឡុងពេលត្រីមាសទី១នៃការបង្រៀនរបស់ខ្ញុំ ខ្ញុំកំពុងដើរតាមយ៉សាលារៀន នៅពេលនោះ ខ្ញុំបានកត់សម្គាល់ឃើញថា ថ្នាក់រៀនមួយកំពុងមានសូរសព្ទអឺងកង។ សិស្សទាំងឡាយកំពុងឈរនៅលើតុហើយស្រែកដាក់គ្នា គ្រវែងសៀវភៅពេញថ្នាក់រៀន ហើយសិស្សពីរនាក់កំពុងវាយគ្នាដោយ មានការមិនពេញចិត្តខ្ញុំក៏ដើរយ៉ាងលឿន ចូលតាមទ្វារបង្ហាញអារម្មណ៍តានតឹងខ្លាំង និងស្រែកថា អង្គុយចុះយ៉ាងស្ងៀមស្ងាត់ ហើយរង់ចាំគ្រូអ្នក។ សម្តីនោះ ត្រូវបានស្វាគមន៍ដោយសំណើចយ៉ាងខ្លាំងពីសិស្សក្នុងថ្នាក់រៀន។ ពួកគេបង្អួលដោយរីករាយសំដៅទៅគ្រូ ដែលត្រូវបានរុយផ្ទប់ទៅនឹងជ្រុងមួយ ដោយសិស្សពីរនាក់នៅក្នុងថ្នាក់រៀន។

គ្រូមួយចំនួន មានបញ្ហាខាងវិន័យយ៉ាងធ្ងន់ធ្ងរ ផ្ទុយទៅវិញ គ្រូផ្សេងទៀតបង្កើតបរិយាកាសក្នុងថ្នាក់រៀន ដែលនាំទៅដល់ការសិក្សា ដោយមានការខិតខំប្រឹងប្រែងដាក់ស្តែងតិចតួច។ តើពួកគាត់ធ្វើយ៉ាងដូចម្តេចទៅ? ស្ពានសម្រាប់ឆ្លងពីភាពចលាចល ទៅកាន់សណ្តាប់ធ្នាប់នៅក្នុងថ្នាក់រៀន មាន៤ផ្នែក ដែលផ្នែកនីមួយៗ ត្រូវស្ថិតនៅកន្លែងមួយ ប្រសិនបើអ្នកត្រូវដឹកនាំថ្នាក់រៀនឱ្យមានឥទ្ធិពល។ ទាំងនេះគឺៈ

១-មេរៀនមានប្រសិទ្ធភាព ដោយពឹងផ្អែកទៅលើកម្មវិធីសិក្សា ដែលមានការរៀបចំបានល្អ។

២-បំណិនរៀបចំចាត់តាំងបានល្អ។

៣-ទំនាក់ទំនងគ្រូ-សិស្សបានល្អ។

៤-វិន័យមានប្រសិទ្ធភាព។

ចំណុច៣ដំបូង មិនអាចត្រូវបានគេមើលរំលងទេ។ ការលំបាកខាងវិន័យភាគច្រើនបំផុត ដែលទទួលបានបទពិសោធដោយគ្រូទាំងឡាយ នៅក្នុងថ្នាក់រៀន គឺត្រូវបានបង្កើតមុនពេលមេរៀនបានចាប់ផ្តើម។ វាមានការជាប់ពាក់ព័ន្ធនឹងកិច្ចតែងការរបស់គ្រូ។ កត្តាដែលពាក់ព័ន្ធដល់ចលករសិក្សា គួរតែត្រូវបានផ្តល់ឱ្យតាមការគិតពិចារណាយ៉ាងដិតដល់។ ការសិក្សារបស់សិស្ស គួរតែមានការចាប់អារម្មណ៍ដោយ មានការពាក់ព័ន្ធដល់សកម្មភាពសិស្សដ៏សំបូរបែប។ គួរតែមានអ្វីមួយសម្រាប់សិស្សទាំងអស់គ្នាធ្វើ នៅគ្រប់ពេលវេលា ហើយស្តង់ដារនៃការងារមិនគួរលំបាក ឬងាយស្រួលពេកទេសម្រាប់សិស្សនៅក្នុងថ្នាក់រៀន។ គួរតែមានការលើកទឹកចិត្តឱ្យបានទៀងទាត់ និងច្រើនដង ដូចជា ការសរសើរ និងការ

លើកទឹកចិត្ត (Praise and encouragement) សម្រាប់ការប្រឹងប្រែងរបស់សិស្ស។

ការជួយដាក់ស្តែងក្នុងការសម្រេចឱ្យបានតុល្យភាពនេះ អាចត្រូវបានរកឃើញនៅក្នុងផ្នែកផ្សេង ទៀតនៃសៀវភៅនេះ ពីព្រោះនៅពេលនេះ យើងនឹងសម្លឹងមើលចំណែក៣ផ្សេងទៀតនៃស្ថានចម្ងង។

## ៣-ការរៀបចំថ្នាក់រៀន

គ្រូបង្រៀនដែលមានបទពិសោធមិនចាំបាច់ដោះស្រាយបញ្ហាដូចនេះទេ ពួកគាត់អាចបង្ការបញ្ហា ទាំងឡាយ មិនឱ្យកើតមានឡើងទេ។ ការរៀបចំថ្នាក់រៀនបានល្អ អាចធ្វើឱ្យមេរៀន ប្រព្រឹត្តទៅដោយមានភាពរលូន ដើម្បីឱ្យទំនាក់ទំនងល្អ អាចដុះដាលឡើងតាមបទពិសោធវិជ្ជមាន។

### ក-ក្បួនច្បាប់ និងរបៀបរបប

គ្រូទាំងអស់សុទ្ធតែមានក្បួនច្បាប់ និងរបៀបរបបរបស់ខ្លួន ទោះបីជាគាត់មិនបានបង្ហាញចេញមកខាងក្រៅដ៏ដោយ។ ចូរគិតអំពីវាដោយយកចិត្តទុកដាក់ បញ្ជាក់បង្ហាញវាដោយច្បាស់លាស់ និងបង្ហំវា ដោយសមស្រប។ តើអ្នកចង់ឱ្យសិស្សប្រគល់កិច្ចការនៅថ្ងៃចន្ទឬថ្ងៃព្រហស្បតិ៍? តើអ្នកចង់ឱ្យសិស្សលើកដៃឆ្លើយសំណួរឬ? នៅក្នុងអំឡុងពេលប្រតិបត្តិ តើអាចឱ្យសិស្សនិយាយគ្នាបានដែរឬទេ?

ក្បួនច្បាប់ និងរបៀបរបបរបស់អ្នកនឹងត្រូវការពេលដើម្បីបង្កើត និងគួរតែពឹងផ្អែកទៅលើការអប់រំសុវត្ថិភាព និងសីលធម៌ មិនមែនទៅលើលក្ខណៈពិសេសបុគ្គល (Personal idiosyncrasies) នោះទេ។

ពិតហើយអ្វីដែលត្រូវបានអនុញ្ញាតឱ្យធ្វើ នៅក្នុងពេលរៀនមេរៀនរបស់អ្នក នឹងត្រូវបានសម្រេច ចិត្តតាមអ្វីដែលអ្នកធ្វើ មិនមែនតាមអ្វីដែលអ្នកនិយាយទេ។ ប្រសិនបើអ្នកនិយាយថា គួរតែមិនមានការ និយាយគ្នា នៅពេលដែលអ្នកកំពុងនិយាយ ប៉ុន្តែ ចូរកុំបង្ខំរឿងនេះអញ្ចឹងក្បួនច្បាប់ នឹងមិនដំណើរការ ទៅរួចទេ ហើយអ្នកគួរតែដើរសំដៅទៅរកសិស្សដែលកំពុងនិយាយគ្នាមិនសមរម្យនោះ ភាពមិនម៉ឺងម៉ាត់របស់អ្នកនឹងមានការតូចចិត្ត។ ហេតុអ្វីជ្រើសរើសតែខ្ញុំ មិនមែនមានតែខ្ញុំម្នាក់នោះទេ? ប្រសិនបើអ្នកបដិសេធដោយម៉ឺងម៉ាត់ ដើម្បីទទួលយកការរួមចំណែកពីសិស្សដែលហៅ ប៉ុន្តែទទួលយក វាពីសិស្សពីសិស្សដែលលើកដៃ ដូច្នោះការលើកដៃ (hand-raising) ក្លាយជាក្បួនច្បាប់មួយ។

ថាតើអ្នកបង្កើតក្បួនច្បាប់ បានដាក់លាក់ឬអត់នោះ ចូរគិតថាវានឹងត្រូវ

បានគេសាកល្បង និង មានភាពម៉ឺងម៉ាត់ក្នុងការលើកទឹកចិត្ត។ រឿងនេះ ហាក់ដូចជាធ្វើឱ្យមានការខឹងសម្បារ និងឯការប្រើប្រាស់ពេលវេលានៅពេលដំបូង ប៉ុន្តែ វាជា ការ ដាក់ ទុន យ៉ាង សំខាន់ ក្នុង សណ្តាប់ធ្នាប់ នាពេលអនាគត។ ក្បួនច្បាប់ និងអាកប្បកិរិយា ត្រូវបានគ្រប់គ្រងតាមករណីច្បាប់ ដែលនឹងត្រូវបានគេ បង្កើតតាមភាពម៉ឺងម៉ាត់ឥតមេត្តា (Ruthless consistence)។ ជួនកាលក្បួនច្បាប់ មានករណីលើកលែង ប៉ុន្តែ មិនមានច្រើនទេ។ ចូរធ្វើឱ្យមានភាពជឿជាក់ថា អ្នកមានភាពត្រឹមត្រូវ បន្ទាប់មក ចូរមានភាពម៉ឺងម៉ាត់។ គ្រូដែលមាន ប្រសិទ្ធភាព និងបទពិសោធ ត្រូវចេះផ្តល់ដំបូន្មានឱ្យគេតាមរបៀបកំប្លែងថា ចូរស្តាប់លេសដោយការយក ចិត្តទុកដាក់ចាប់អារម្មណ៍ និង សេចក្តីមេត្តា បន្ទាប់មក ចូរកុំយកចិត្តទុកដាក់នឹងវា។

ជួនកាល វាមានតម្លៃនឹងចរចារអំពីក្បួនច្បាប់ និងរបៀបរបបជាមួយសិស្ស: តើអ្នកចង់ប្រគល់កិច្ចការ នៅថ្ងៃចន្ទ ឬថ្ងៃព្រហស្បតិ៍? គ្រូមួយចំនួនផ្តល់បញ្ហាទៅឱ្យក្រុមសិស្ស។ ចូរមានភាពម៉ឺងម៉ាត់ស្មើៗ គ្នាក្នុងក្បួនច្បាប់លើកទឹកចិត្តដែលបានសម្រេចដោយក្រុម។ ពេលណាដែលក្បួនច្បាប់ ត្រូវបានបង្កើតនោះ អ្នកអាចបត់បែនវាបន្តិចបន្តួច ប៉ុន្តែ ចូរមានភាពយុត្តិធម៌ និងម៉ឺងម៉ាត់។

ប្រសិនបើអាចធ្វើទៅបាន គួរតែមានគោលវិធីដូចគ្នាមួយ ចំពោះក្បួនច្បាប់ និងរបៀបរបបពីគ្រូ បង្រៀនទាំងអស់ដែលសិស្សទាំងឡាយ បានទទួលបទពិសោធ។

នេះជាក្បួនច្បាប់ និងរបៀបរបបមួយចំនួន ដែលគេបានប្រើ សម្រាប់សិស្សអាយុ ១៧ឆ្នាំ និង អាចសម្រាប់សិស្សដែលមានវ័យប្រហែលគ្នាផងដែរ៖

-កុំនិយាយឱ្យសោះ ប្រសិនបើខ្ញុំកំពុងនិយាយ។

-ក្បួនច្បាប់សុខភាព និងសុវត្ថិភាពត្រូវបានគោរព ដូចជាហាមរត់នៅក្នុងថ្នាក់រៀន។

-នៅពេលដែលធ្វើការងារជាបុគ្គល ឬជាក្រុម សិស្សអាច៖

.និយាយទៅកាន់សិស្ស នៅជិតគ្នាអំពីការងារ។

.ដើរចេញពីកន្លែងរបស់ខ្លួន ដើម្បីនិយាយអំពីការងារជាមួយសិស្សផ្សេង។

-ការងារ ត្រូវប្រគល់ជូនគ្រូ នៅថ្ងៃនីមួយៗនៃសប្តាហ៍។ អវត្តមានច្រើនជាងមួយថ្ងៃ ជាហេតុផលដែលអាចទទួលយកបាន សម្រាប់ភាពយឺតយូរក្នុងការប្រគល់កិច្ចការ។

-ហាមស្តាប់កូនម៉ាញេ និងបិទទូរសព្ទផ្ទាល់ខ្លួន។

-ហាមហូប និងផឹក។

-ហាមសិស្សចេញពីថ្នាក់រៀនដោយគ្មានការអនុញ្ញាត។

ចូរអ្នកសង្កេតមើលថ្នាក់រៀននៅក្នុងសាលា ឬមហាវិទ្យាល័យអ្នក ដូច្នេះអ្នកអាចទទួលអារម្មណ៍ សម្រាប់អាកប្បកិរិយាដែលអាចទទួលយកបាន។ ប្រសិនបើក្តីសង្ឃឹម អ្នកទៅនឹងគ្រូផ្សេងទៀតនោះ រឿងនេះ នឹងធ្វើឱ្យជីវិតអ្នកមានភាពងាយស្រួលជាង។

**ខ-មុនពេលសិស្សមកដល់**

ចូរមកដល់ថ្នាក់រៀនមុនសិស្ស ហើយត្រូវរៀបចំអ្វីៗដែលអ្នកត្រូវការជាស្រេច។ ប្រសិនបើអ្នក ជាគ្រូវិទ្យាសាស្ត្រ អ្នកគួរតែបានធ្វើការពិសោធតាមទម្រង់ការណាមួយ ដែលអ្នក ឬសិស្សក្នុងថ្នាក់រៀន អ្នកនឹងអនុវត្ត។ រៀបចំទុកដាក់អ្វីៗដែលអ្នកត្រូវការ សម្រាប់មេរៀនដោយមានរបៀបរៀបរយ ដូច្នេះ អ្នកអាចរកវាឃើញ និងត្រៀមរៀបចំក្តារខៀន សម្រាប់នាទីដំបូងនៃមេរៀន។

នៅពេលដែលសិស្សមកដល់ អ្នកអាចរៀបចំឱ្យគេចូលថ្នាក់ ហើយអង្គុយតាមកន្លែង។ ចូរចាប់ផ្តើមទៅតាមពេលវេលា។ ការរង់ចាំសិស្សមកយឺត គឺមានភាពអយុត្តិធម៌ ចំពោះសិស្សដែលមករៀនទាន់ ពេលវេលា ហើយលើកទឹកចិត្តអ្នកមកយឺតឱ្យមករៀនទាន់ពេលនា នៅថ្ងៃខាងមុខ។

**គ-ការរៀបចំឱ្យមានភាពស្ងប់ស្ងាត់**

ការទទួលបាន និងការរក្សាភាពស្ងប់ស្ងាត់ គឺជារឿងសំខាន់។ វាមានតម្លៃណាស់ដែលគេយកចិត្ត ទុកដាក់អំពីរឿងនេះ នៅពេលដែលអ្នកជួបក្រុមថ្មីជាលើកដំបូង។ ពេលវេលាដែលបានចំណាយ នៅដំណាក់កាលនេះ នឹងជាការដាក់ទុនដ៏ល្អប្រសើរ។ ប្រសិនបើអ្នកមិនធ្វើឱ្យមានភាពស្ងប់ស្ងាត់ នៅក្នុងមេរៀនជាលើកដំបូងនោះ អ្នកនឹងមិនអាចធ្វើរឿងនេះបានជារៀងរហូត ហើយទោះណាជាសិស្សអាចស្តាប់ ឮអ្នក នៅក្នុងមេរៀននៅពេលក្រោយមកក៏ដោយ ក៏គេនឹងមិនយកចិត្តទុកដាក់ស្តាប់ទេ។

ចូររក្សាឱ្យមានភាពស្ងប់ស្ងាត់ ហើយបន្ទាប់មកចូររង់ចាំឱ្យភាពស្ងប់ស្ងាត់នេះ កើតមានឡើងសិន តែទោះជាយ៉ាងណាក៏ដោយ ក៏វាត្រូវការពេលយូរដែរ។ ប្រសិនបើចាំបាច់ ចូររំឭកឡើងវិញ ដើម្បីឱ្យមានភាពស្ងប់ស្ងាត់ ហើយចូរប្រើប្រាស់បច្ចេកទេសខាងក្រោម ដើម្បីទទួលបានការពង្រឹងវា។ ចូរកុំចាប់ផ្តើមបង្រៀន លុះណាតែមានភាពស្ងប់ស្ងាត់ដាក់ស្តែងកើត

មានឡើង ហើយសិស្សទាំងអស់ កំពុងសម្លឹងទៅរកអ្នក។ ចូរកុំចាប់ផ្ដើមបង្រៀន នៅពេលដែលសិស្សមានសំឡេងឡូឡាឱ្យសោះ។ ប្រសិនបើអ្នកធ្វើដូច្នោះ សិស្សគិតថា អ្នកអនុញ្ញាតឱ្យគេនិយាយគ្នាបានទៅតាមចំណូលចិត្ត ហើយជាលទ្ធផល សូម្បីតែសិស្សដែល មានភាពស្ងប់ស្ងាត់ពីពេលដំបូង ក៏នឹងចាប់ផ្ដើមនិយាយគ្នាដែរហើយ មិនយូរមិនឆាប់គេក៏ចាប់ផ្ដើមនិយាយ គ្នារំខានអ្នកទៀត។

ប្រសិនបើការរង់ចាំ ធ្វើឱ្យអ្នកមានអារម្មណ៍មិនល្អ កុំបង្ហាញវាចេញមកក្រៅ។ ចូរកុំខឹង ឬធ្វើឱ្យមានភាពហួសហេតុ ព្រោះនេះជារឿងធ្វើឱ្យខូចប្រយោជន៍។ គេនឹងចាប់អារម្មណ៍ថាអ្នកមិនអាចគ្រប់គ្រងអារម្មណ៍ខ្លួនឯងបាន។ ជំនួសរឿងនេះ ធ្វើហាក់ដូចជាថា គេភ្លេចអ្វីមួយនៅពេលដែលគេឡូឡាៈ

-អ្នកទាំងអស់គ្នា ចូររង់ចាំស្ដាប់ ថាតើសូភីត្រូវនិយាយអំពីអ្វី។

-ទេ សុំទោស យើងមិនអាចចាប់ផ្ដើមរៀនបានទេ ពីព្រោះយើងមិនទាន់មានភាពស្ងប់ស្ងាត់ទេ។

ការសម្រេចបានភាពស្ងបស្ងាត់ ចូរស្វែងយល់ឱ្យបានយូរបន្តិច ហើយបន្ទាប់មកចាប់ផ្ដើមនិយាយ អំពីដែលអ្នកចង់និយាយ។ប្រសិនបើអ្នកណាម្នាក់និយាយនៅពេលដែលអ្នកកំពុងនិយាយ ចូរបញ្ឈប់ត្រឹម ពាក់កណ្ដាលល្បះ ហើយសម្លឹងមើលគេ រហូតដល់គេឈប់និយាយគ្នា។ ពួកគេនឹងដឹងថា រឿងនេះ គួរឱ្យខ្មាសអៀន ហើយទំនងជានឹងឈប់ភ្លាមៗ។ ប៉ុន្តែ ប្រសិនបើចាំបាច់ ចូរប្រើឈ្មោះគេ ឬសុំឱ្យមានភាពស្ងប់ស្ងាត់ម្ដងទៀត។ មានតែធ្វើឱ្យមានភាពស្ងប់ស្ងាត់ឡើងវិញទេ ទើបអ្នកគួរតែនិយាយបន្តទៅទៀត ដោយចាប់ផ្ដើមល្បះដែលអ្នកបានឈប់និយាយនៅពេលមុន។ ការនិយាយគួរចាប់ផ្ដើមឡើងវិញ ចូរធ្វើដូចពេលមុន។ ភ្លាមៗនោះ សិស្សភាគច្រើន នឹងដឹងថា ពួកគេមិនអាចនិយាយ ដោយគ្មានការយកចិត្តទុកដាក់ភ្លាម ដល់ខ្លួនគេ ហើយគេនឹងឈប់ព្យាយាមធ្វើបែបនេះ។

ប្រសិនបើមានអ្នកអាក់អន់ចិត្តបែបមានៈនោះ (persistent offender) ចូរពន្យល់ថា វាមិនអាចនិយាយផង ស្ដាប់ផងក្នុងពេលតែមួយនោះទេ ចូរឈរនៅជិតពួកគេ ហើយប្រសិនបើចាំបាច់ ចូរគំរាមផ្លាស់កន្លែងពួកគេ។ បច្ចេកទេស ត្រូវបានដោះស្រាយនៅផ្នែកខាងក្រោម ប៉ុន្តែ អ្វីក៏ដោយដែលអ្នក ធ្វើចូរកុំបោះបង់ចោល។ ទោះជាយ៉ាងណាក៏ដោយ ចូរកុំសង្ឃឹមខ្លាំងពេក។ ក្រុមមួយចំនួនអាចផ្ដោតអារម្មណ៍តាមន័យពាក្យតែម្យ៉ាង ទៅលើ

សម្តីគ្រូ សម្រាប់រយៈពេល២ ឬ៣នាទី ឬក៏អាចតិចជាងនេះ។ ប្រសិនបើអ្នកមានក្រុមដូច្នោះ ចូរកុំពឹងផ្អែកទៅលើការប្រើប្រាស់សម្តីគ្រូ ជាមួយថ្នាក់រៀនទាំងមូល។ ចូរនិយាយទៅកាន់ពួកគេជាក្រុមតូចៗ ហើយធ្វើទំនាក់ទំនងជាមួយក្តារខៀន ឬក៏អាចប្រើប្រាស់ក្រដាសធ្វើការផ្សារផងដែរ។

**ឃ-នៅពេលចាប់ផ្តើមរៀន**

នៅពេលចាប់ផ្តើម៥នាទីដំបូងនៃមេរៀនណាមួយ គឺជារឿងសំខាន់ក្នុងការកំណត់បរិយាកាស សម្រាប់មេរៀនបន្តទៅទៀត។ប្រសិនបើអ្នកចង់ធ្វើឱ្យថ្នាក់រៀន ដែលមានភាពអសកម្មទៅជាសកម្មនោះ ( Enliven a sleepy class) ដូច្នោះ ចូរចាប់ផ្តើមដោយមានភាពសកម្ម។ ប្រសិនបើអ្នកចង់ធ្វើឱ្យក្រុមឡូឡាមានភាពស្ងប់ស្ងាត់ (Quieten a noisy down) ចូរចាប់ផ្តើមដោយស្ងប់ស្ងាត់។

ប្រសិនបើថ្នាក់រៀនមួយ មានភាពឡូឡាជាពិសេសនោះ ចូរព្យាយាមបង្កើតសកម្មភាពមួយដំបូង ដែលសិស្សកំពុងសិក្សាតែម្នាក់ឯង ដោយមិនចាំបាច់មានជំនួយពីអ្នក។ ពួកគេអាចចម្លងវិញ្ញាក្រោមនៅលើក្តារខៀន ធ្វើលំហាត់ពីក្នុងសៀវភៅសិក្សា ឬបញ្ចប់កិច្ចការអ្វីមួយពីមេរៀនចុងក្រោយ។ ដូច្នោះ អ្នកអាចផ្តោតអារម្មណ៍១០០% ដើម្បីធ្វើឱ្យថ្នាក់រៀនកាន់តែមានភាពស្ងប់ស្ងាត់ឡើង និងធ្វើឱ្យថ្នាក់រៀនមានបរិយាកាសសិក្សាស្ងប់ស្ងាត់ ព្រមទាំងដោះស្រាយជាមួយលូស៊ី ដែលបានមកដល់យឺត ដោយខកខានរៀនមេរៀនរបស់នាង។ នៅពេលដែលថ្នាក់រៀនមានភាពស្ងប់ស្ងាត់អស់រយៈពេល៥នាទីនោះ អ្នកបានកំណត់បរិយាកាសសម្រាប់មេរៀនដែលនៅសល់។

**ខ-ការបង្រៀន**

ចូរធ្វើឱ្យមានភាពស្ងប់ស្ងាត់ ហើយធ្វើឱ្យមានភាពជឿជាក់ថា សិស្សក្នុងថ្នាក់រៀនទាំងអស់សម្លឹង ទៅរកអ្នក។ គ្រូមួយចំនួនជាពិសេសគ្រូទាំងឡាយ ដែលត្រូវប្រកួតប្រជែងនឹងសំឡេងឡូឡាពីម៉ាស៊ីនមាន របៀបទាក់ទាញអារម្មណ៍ដដែលៗ ដូចជាទះដៃបីដង។ និយាយឱ្យខ្លីទៅ ចូរមានភាពច្បាស់លាស់ និងវិជ្ជមាន។ សំឡេងគួរតែមានភាពម៉ត់ចត់ ជឿជាក់ និងរីករាយ។ ប្រសិនបើអ្នកសុំឱ្យសិស្សក្នុងថ្នាក់រៀន ផ្លាស់ប្តូរស្ថានភាពនោះ ចូរសុំឱ្យគេនៅស្ងៀមរហូតដល់អ្នកបញ្ចប់មេរៀន។ នៅពេលដែលអ្នកបញ្ចប់មេរៀន ហើយនោះ ចូរសង្ខេបមេរៀន៖

គ្រូទះដៃពីរបីដង៖ សូមអ្នកទាំងអស់គ្នាយកចិត្តទុកដាក់ សោភា សុខា! សូមមើលមកនេះ។ គ្រូ រង់ចាំឱ្យមានភាពស្ងប់ស្ងាត់៖ ឥឡូវនេះ នៅពេលដែលខ្ញុំ

ប្រាប់អ្នក ខ្ញុំចង់ឱ្យមនុស្សម្នាក់មកពីក្រុមនីមួយៗ ទៅប្រមូលយកឧបករណ៍ពីបង់អង្គុយ ហើយម្នាក់ផ្សេងទៀត ទៅជ្រើសរើសយកឧបករណ៍ផ្សេងៗទៀត ពីផ្នែកខាងក្រោយបន្ទប់ពិសោធ។ អ្នកដែលនៅសល់ក្នុងក្រុមអ្នក នឹងត្រៀមរៀបចំតុសម្រាប់លទ្ធផល។ ម្នាក់រៀបចំឧបករណ៍ម្នាក់ទៀតរៀបចំឧបករណ៍ពីបន្ទប់ពិសោធន៍ ហើយម្នាក់ទៀតរៀបចំតុ។ សូមអ្នករៀបចំចាប់ផ្តើមទៅ។

ជាញឹកញាប់ ប្រសិនបើអ្នកទាមទារឱ្យមានការផ្លាស់ទីកន្លែង នៅផ្នែកខាងមុខនៃថ្នាក់រៀនសម្រាប់ការបកស្រាយនោះ វាមានតម្លៃពិចារណានូវស្ថានភាពដែលមិនប្រែប្រួល សម្រាប់សិស្សដែលផ្លាស់កន្លែង។

ចូរកុំធ្វើការត្អូញត្អែរជាទូទៅដដែលៗ ដូចជាលឿនឡើង អ្នករាល់គ្នាចាប់ផ្តើមសិក្សាទៅ។ ចូរបង្រៀនជាទូទៅបន្ទាប់មក ចូរជ្រើសរើសបុគ្គលទាំងឡាយដែលមិនគោរព តាមការហៅឈ្មោះ ឬតាមទំនាក់ទំនងកែវភ្នែក៖ លឿនឡើងចិន្តា ចាប់ផ្តើមរៀនទៅ។

អ្នកទាំងឡាយដែលបង្រៀនសិស្សគួរតែផ្តល់ឧទាហរណ៍។ ប្រសិនបើអ្នកចង់ឱ្យសិស្សមានរបៀបរៀបរយ តាមរបៀបមួយដែលគេរៀបចំការងាររបស់ពួកគេនោះ ដូច្នេះចូរផ្តល់ដំបូន្មាន នៅពេលដែលកំពុងសរសេរ នៅលើក្តារខៀន។ ប្រសិនបើអ្នកចង់ឱ្យពួកគេប្រើប្រាស់ទម្រង់ការសុវត្ថិភាពពិតប្រាកដនោះ ដូច្នេះចូរប្រើពួកគេដោយខ្លួនឯង។ កុំឱ្យសិស្សអ្នកចេញពីថ្នាក់រៀន មុនពេលដែលមេរៀនបានបញ្ចប់។ វា អាចផ្តល់ភាពលំបាក។ ប្រសិនបើពួកគេបានបញ្ចប់សកម្មភាពសិក្សា ចូរអ្នកព្យាយាមរំឭកតាមចំណោទសំណួរ។

## សន្និដ្ឋាន

ការគ្រប់គ្រងថ្នាក់រៀន គឺជាទិដ្ឋភាពដ៏សំខាន់នៃការបង្រៀនប្រកបដោយប្រសិទ្ធភាព ព្រោះវាជះឥទ្ធិពលដោយផ្ទាល់ដល់អាកប្បកិរិយារបស់សិស្ស ការចូលរួម និងភាពជោគជ័យនៃការសិក្សា។ ថ្នាក់រៀនដែលគ្រប់គ្រងបានល្អ ជំរុញការគោរពវិន័យ និងបរិយាកាសសិក្សាវិជ្ជមាន ដែលសិស្សអាចរីកចម្រើន។ គ្រូបង្រៀនដែលប្រើច្បាប់ច្បាស់លាស់ ការពង្រឹងវិជ្ជមាន និងយុទ្ធសាស្ត្រទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព អាចកាត់បន្ថយការរំខាន និងបង្កើនឱកាសសិក្សា។ ទីបំផុត ការគ្រប់គ្រងថ្នាក់រៀនដែលទទួលបានជោគជ័យ ជួយបង្កើតបរិយាកាស ដែលមានរចនាសម្ព័ន្ធ

| | |
|---|---|
| ប៉ុន្តែ អាចបត់បែនបាន ដែលសិស្សមាន អារម្មណ៍ថាត្រូវបានគាំទ្រ និងលើក | ទឹកចិត្តឱ្យឈានដល់សក្តានុពលពេញលេញរបស់ពួកគេ។ |

## ឯកសារយោង


1. Wong, H. K., & Wong, R. T. (2009). *The first days of school: How to be an effective teacher* (4th ed.). Harry K. Wong Publications.
2. Killen, Roy. (2003). *Effective teaching strategies: Lessons from research and practice.* Social science press.
3. Marzano, R. J. (2007). *Classroom management that works: Research-based strategies for every teacher*. ASCD.
4. Wong, H. K. (2004). *The classroom management book*. Harry K. Wong Publications.
5. Nelsen, J. (2006). *Positive discipline in the classroom: Developing mutual respect, cooperation, and responsibility in your classroom* (3rd ed.). Three Rivers Press.
6. Fay, J., & Funk, D. (2010). *Teaching with love and logic: Taking control of the classroom* (2nd ed.). Love and Logic Press.